# ចលាចលក្នុងពិភពគំនិត នៅទីក្រុងប៉ារីស

ដោយ សុទ្ធ-ប៉ូលិន ⋆ ថ្ងៃទី១៨ តុលា ២០០៥

នៅថ្ងៃទី១៧ មេសា ១៩៧៥, ក្រុមបញ្ញជនខ្មែរនៅទីក្រុងប៉ារីសមានសេចក្ដីធូរស្រាលក្នុងដើមទ្រូង ដោយសង្គ្រាមនៅប្រទេសកម្ពុជា បានត្រូវបញ្ចប់រួចហើយ, សូមលាហើយ លាដាច់អាល័យ ចំពោះទិដ្ឋភាពនៃមហន្តរាយរបស់ជនជាតិខ្មែរ, ទិដ្ឋភាពនៃថ្លុកឈាម ដែលបង្កបង្កើតឡើងដោយសារគ្រាប់រ៉ុក្កែត ធ្លាក់រពុយតាមផ្លូវនៃទីក្រុងភ្នំពេញ ជាពិសេសនៅម្ដុំផ្សារចាស់ ដែលពួកយើងបានឃើញ ដោយសេចក្ដីតក់ស្លុត តាមទូរទស្សន៍បារាំង ។ ខ្លួនខ្ញុំផ្ទាល់មានមនោសញ្ចេតនា បែងចែកជាពីរដែលច្រាស់ទិសគ្នា ៖

ម្យ៉ាង ខ្ញុំក៏មានសេចក្ដីធូរស្រាលរីករាយក្នុងចិត្តផងដែរ ដោយនៅទីបំផុតប្រជាជនខ្មែរ បានស្គាល់ក្ដីសុខសន្តិភាព... ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ខ្ញុំមានចិត្តល្វីងជូរចត់ពន់ប្រមាណ ដោយខ្លួនខ្ញុំស្ថិតនៅក្នុងគណបក្សរបស់ពួកអ្នកចាញ់ (ពោលគឺខ្ញុំធ្លាប់ជាកូនចៅសហការីផ្ទាល់របស់ឧត្ដមសេនិយលន់-នល់ កាលក្នុងរយៈព្រឹត្តិការណ៍ថ្ងៃទី១៨មិនា១៩៧០) ។ ខ្ញុំមានអារម្មណ៍ថា ពួកអ្នកចាញ់គេ មិនដែលបានទទួលសេចក្ដីសុខសប្បាយសោះឡើយ ។ ពួកចាញ់គេ ចាញ់ល្បែងក្ដី ចាញ់សង្គ្រាមក្ដី មានជម្ងឺចាញ់ក្ដី... ចាញ់ល្បិចគេក្ដី, ចាញ់បោកខ្លួនឯងក្ដី (ខកចិត្តឆ្គួតវង្វេង) ឲ្យតែមានឈ្មោះថា«ចាញ់» គឺមានវាសនាអភ័ព្វដូចគ្នាទាំងអស់ ។

នៅព្រឹកថ្ងៃទី១៧មេសា១៩៧៥នោះ ខ្ញុំកំពុងឈរពិគ្រោះគ្នាជាមួយមិត្តភក្ដិម្នាក់ឈ្មោះលោក ស៊ិន-គិមស៊ុយ អំពីព្រឹត្តិការណ៍ស្រុកខ្មែរ នៅតាមផ្លូវ Bd Raspail ស្រាប់តែឃើញលោក ឱ-ការ៉េត (លោកឱ-កាវ៉េត ហើយនិងលោកស៊ិន-គឹមស៊ុយ ជា«សមមិត្ត»របស់ខ្ញុំ ក្នុងសារពត៌មាន«នគរធំ» ដែលខ្ញុំបានបោះផ្សាយនៅភ្នំពេញក្នុងសម័យសាធារណរដ្ឋ) ...លោកឱ-កាវ៉េត កាន់អត្ថបទសារទូរលេខមួយ សំរាប់ថ្លែងកោតសរសើរជោគជ័យដ៏ត្រចះត្រចង់ របស់ឯកឧត្ដមខៀវ-សំផន ដើម្បីយកមកឲ្យយើងចុះហត្ថលេខា ។ លោកស៊ិន-គឹមស៊ុយ បែបរៀងអេះអុញ ពីព្រោះជាយូរខែណាស់មកហើយ លោកតែងនិយាយប្រាប់ខ្ញុំថា ៖ «ខៀវ-សំផនកាចសាហា

វណាស់ ! អានេះកាចសាហាវណាស់ !» ។

ស៊ុយក៏និយាយថា ៖

- រឿងនេះ... ស្រេចតែប៉ូលិនទេ... បើយើងស៊ីញ៉េត្រូវស៊ីញ៉េទាំងបីនាក់ ។

- ឲ្យការ៉េតស៊ីញ៉េតែម្នាក់ឯងទៅ (យោបល់របស់ខ្ញុំ) ។

- មិនបានទេ (ការ៉េតពោល) បើខ្ញុំស៊ីញ៉េតែម្នាក់ឯង, អត្ថបទនេះគ្មានតម្លៃទេ។

- ខ្ញុំមិនស៊ីញ៉េទេ (ខ្ញុំពោល)... ពីព្រោះវាឥតប្រយោជន៍, ពួកយើងសុទ្ធសឹងជាពួកចាញ់គេ ។

ស៊ុយជាអ្នកកណ្តាល, ចំណែកការ៉េតនិងខ្ញុំប្រកាន់ជំហររៀងខ្លួន អស់មួយព្រឹកធំ ។ ការ៉េតបានយល់ថា ខ្ញុំជាអត្តទត្តបុគ្គល, គិតតែប្រយោជន៍ខ្លួនឯង, មិនព្រមដាក់ខ្លួន មិនព្រមគិតដល់សេចក្តីសុខរបស់ប្រជាជន ។ នៅទីបំផុត លោកឌី-ការ៉េតក៏បានបញ្ចេញយោបល់មួយយ៉ាងសំបើម ដូចជាអន្លង់របស់យក្ស ។

- បើប៉ូលិនឯងមិនស៊ីញ៉េទេ... ពួកយើងនឹងក្លាយទៅជាឃាតករ... ពីព្រោះគេនឹងសម្លាប់បងប្អូនយើងនៅក្នុងស្រុកអស់រលីងហើយ...។

ខ្ញុំសំរេចចិត្តចុះចាញ់ ព្រមទាំងចុះហត្ថលេខានៅក្រោមអត្ថបទនោះ ដោយមានឈ្មោះខ្ញុំនៅពីលើ, ស៊ិន-គឹមស៊ុយជាទី២, ឌី-ការ៉េតជាទី៣ ។

៣-៤ថ្ងៃក្រោយមក ខ្ញុំបានទទួលពត៌មានថា លោកខៀវ-សំផនបានបញ្ជាឲ្យជម្លៀសប្រជាជនខ្មែរ ចេញអស់ពីទីក្រុងភ្នំពេញ ។ ពេលនោះ ខ្ញុំធ្លាក់ថ្លើមក្តុក ! ខ្ញុំដឹងច្បាស់ណាស់ថា លោកខៀវ-សំផនគឺមិនបានអានអត្ថបទសាទូរលេខរបស់យើងទេ... ប៉ុន្តែខ្ញុំនៅតែមានការមន្ទិលសង្ស័យ...ប្រសិនបើយើងមិនបានផ្ញើអត្ថបទគាំទ្រទៅគាត់ទេ ប្រហែលជាគាត់មិនមានអាការៈសាហាវដល់ម្លឹងពេកទេ ។

ខ្ញុំមានការរអៀសខ្លួនខ្លាំងណាស់ ។ យើងជាអ្នកបំរើសាធារណរដ្ឋរហូតដល់ថ្ងៃទី១៧មេសា១៩៧៥ ។ គ្រាន់តែលោកឧត្តមសេនិយលន់-នល់ដួលរលំភ្លាមកាលណា ពួកយើងស្រាប់តែបត់ក្បាល១៨០អង្សា ទៅគាំទ្រឯកឧត្តមខៀវ-សំផន ។ នេះជាឧក្រិដ្ឋកម្មក្នុងពិភពគំនិត, ជាការមើលស្រាលដល់បញ្ញារបស់លោកខៀវ-សំផន... ពីព្រោះយើងចាត់ទុករូបគាត់ជាស្វា ។ មានត្រង់កន្លែងណាទៅ ដែលឯ.ឧ. ខៀវ-សំផនមើលមិនឃើញថា អត្ថបទរបស់ពួកយើងជាសេចក្តីភូតភរ ។

លោកម៉ម-សូណាង់ដូ, ឪពុកមារបស់ខ្ញុំម្នាក់ ព្រមទាំងជាមិត្តរួមថ្នាក់នៅសាលាព្រះពុទ្ធមានបុណ្យ កាលយើងនៅក្មេងសេចក្តី (គាត់មានអាយុលើសខ្ញុំតែមួយឆ្នាំប៉ុណ្ណោះ) បានកោតសរសើរថា ខ្ញុំជា«អ្នកនយោបាយដ៏ប៉ិនប្រសប់» នៅពេលដែលគាត់ដឹងថា ខ្ញុំបានចុះហត្ថលេខាគាំទ្រលោកខៀវ-សំផន ។ ជាពិសេស លោកម៉ម-សូណាង់ដូបានយល់ថា ខ្ញុំចេះបត់បែន ចេះសំរបខ្លួនតាមកាលៈទេសៈ ។ ប៉ុន្តែខ្ញុំទទួលយកសេចក្តីសេរសើររបស់ឪពុកមារបស់ខ្ញុំមិនបានទេ ដោយឱកាសនិយម មិនមែនជាចរិកលក្ខណៈរបស់ខ្ញុំទាល់តែសោះ ។

លោកឱ-កាវ៉េត បានលោតទៅមុខមួយជំហានទៀត ។ គឺគាត់បានទៅបំរើអង្គការខ្មែរក្រហមនៅទីក្រុងប៉ារីស ហើយបានប្រាប់ខ្ញុំថា «ពួកយើងទាំងពីរនាក់ គួរតែឈប់ទាក់ទងគ្នាមួយរយៈសិន» ។

ខ្ញុំបានជួបលោកដុកទ័រច្បាប់ ភួង-តុន ។ គាត់បំរុងវិលត្រឡប់ទៅស្រុកវិញ ។ គាត់បានទៅចុះចូលនឹងបក្សខ្មែរក្រហមនៅទីក្រុងប៉ារីស ដែលបានយកគាត់ទៅលត់ដំ ដោយប្រើគាត់ឲ្យទៅធ្វើការហត្ថកម្មបេះផ្លែទំពាំងបាយជូរបារាំង ។ ខ្ញុំបាននិយាយប្រាប់លោកភួង-តុនថា ៖ «បង, គួរតែកុំអាលប្រញាប់វិលទៅស្រុកវិញ...សភាពការណ៍ដូចជាមិនសូវស្រួលសោះ» ។

លោកភួង-តុនស្រាប់តែមានសេចក្តីច្រឡោតយ៉ាងខ្លាំងចំពោះខ្ញុំ ។ មិនត្រឹមតែប៉ុណ្ណោះ បានទៅប្រាប់ពួកបារាំងថា ៖ ខ្លួនខ្ញុំជាភ្នាក់ងាររបស់សេអ៊ីអា ។ ពួករាជការបារាំងក៏បានចាប់ផ្តើមមានសេចក្តីស្អប់ខ្ពើមចំពោះរូបខ្ញុំ ស្ទើរតែបណ្តាលឲ្យខ្ញុំដិកដង្ហើមមិនបាន ។ ជាពិសេសសង្ឃកាតូលិកកុម្មុយនីស្ត François Ponchaud ដែលសរសើរតែពីការស្អាតស្អំរបស់លោកអ៊ិន-តាំ និងបដិវត្តន៍ដ៏រុងរឿងរបស់ខ្មែរក្រហម បានចោទខ្ញុំថាជា «ជនក្រខ្វក់ពុករលួយប្រតិកិរិយាប្រូអាមេរិកាំងនៃរដ្ឋការលន់-នល់» ។ បារាំងម្នាក់ក្នុងក្រសួងសិក្សាធិការបារាំង លោក Bernard Prunières ដែលជួយខ្ញុំឲ្យបានទទួលអាហារូបករណ៍ ដើម្បីធ្វើការសិក្សានៅ Sorbonne ក៏បានផ្តាច់ទំនាក់ទំនងរបស់គាត់ពីរូបខ្ញុំអស់រលីង ។

ជាអកុសល លោកភួង-តុន ដែលបានវិលត្រឡប់ទៅស្រុកវិញ ក៏បានបាត់ស្រមោលសូន្យឈឹង ដូចគេទៅសុំភ្លើងយក្ស ។ ទោះជាយ៉ាងណាក្តី បញ្ញវ័ន្តខ្មែរជាច្រើនរូបនៅពេលនោះ នៅតែបន្តការវេចខ្ចប់ឥវ៉ាន់ដាក់ក្នុងវ៉ាលីស និងប្រមែប្រមូលឯកសារ និងសញ្ញាប័ត្រ-សញ្ញាយើញ និងដាក់ទីឡូ សំរាប់ស្ពាយយកទៅបំរើអង្គការបដិវត្តន៍ ។

ខ្លួនខ្ញុំបានជួបនឹងមិត្តភក្តិម្នាក់ទៀត គឺលោកអៀ-ម៉េងទ្រី ធ្លាប់ធ្វើជាអ្នកតំណាងរាស្ត្រក្នុងសម័យសាធារណរដ្ឋ ព្រមទាំងជាអ្នកនិពន្ធម្នាក់ក្នុងសារពត៌មាន«នគរធំ» ផងដែរ ។ លោកអៀ-ម៉េងទ្រីនៅតែបន្តការសិក្សារបស់លោក ក៏ប៉ុន្តែលោកមានគោលបំណងបញ្ជូនប្រពន្ធកូន ឲ្យត្រឡប់ទៅភ្នំពេញវិញមុនរូបខ្លួនឯង ។ ខ្ញុំបានឲ្យយោបល់ទៅមិត្តខ្ញុំថា... មិនគួរប្រញាប់ពេកទេ គួរតែរង់ចាំលើលស្ថានការណ៍ឲ្យបានច្បាស់លាស់ជាងនេះបន្តិចសិន ។ លោកអៀ-ម៉េងទ្រីក៏បញ្ចេញកំហឹងដាក់ខ្ញុំយ៉ាងខ្លាំងដោយនិយាយថា ៖ «ប៉ូលិនឯងនៅស៊ីបាយអាណានិគមនៅទីនេះហើយ» ។

៥ឆ្នាំក្រោយមក (១៩៨០) លោកអៀ-ម៉េងទ្រីបានមកសំណាក់នៅក្នុងផ្ទះខ្ញុំមួយយប់ (ដែលមានតែបន្ទប់មួយតូចប៉ុនក្តារមឈូស នៅ Quartier Latin) ។ គាត់មានលក្ខណៈប្រហែលតែនាងបដាចារទៅហើយ ។ លោកអៀ-ម៉េងទ្រីនិយាយប្រាប់ខ្ញុំដោយស្រក់ទឹកភ្នែកបណ្តើរផងថា ៖

= បើខ្ញុំជឿប៉ូលិនឯង... ប្រពន្ធកូនខ្ញុំច្បាស់ជានៅមានជីវិតនៅឡើយទេ ។ បងប្អូននៅឯស្រុក បានសរសេរសំបុត្រមកស្ដីបន្ទោសឲ្យខ្ញុំច្រើនគ្នា សឹងតែបណ្ដាលឲ្យខ្ញុំឆ្កួតទៅហើយ ពីព្រោះគេបានឃើញរូបប្រពន្ធនិងកូនខ្ញុំបិទនៅជញ្ជាំង«ទួលស្លែង» ។

★

ព្រឹត្តិការណ៍អស់ទាំងនេះ បានរសាត់បាត់ទៅដូចស្ទឹងហូរចាកចេញទៅឆ្ងាយអស់ចំនួន៣០ឆ្នាំមកហើយ ។ ប៉ុន្តែបើគេឲ្យខ្ញុំនិយាយពីសភាពការណ៍សព្វថ្ងៃវិញ ខ្ញុំនៅតែនិយាយដូចតែពេលថ្ងៃទី១៧មេសា១៩៧០ដូច្នោះ ៖

«ពួកយើងជាពួកចាញ់គេ... តើមានរឿងហេតុអ្វី ដែលគេត្រូវទទួលពួកយើងជាសហការីរបស់គេនោះ ?» ។

ពួកគេជាយក្ស សាងសង់ដល់«អង្គរវត្ត»ទៅហើយ ចំណែកពួកយើងជាសត្វគីង្គក់ ។ «គីង្គក់គរគោក... ជាសត្វស្មោគគ្រោក... ស្បែកវាគគ្រាត... ពណ៌វាគគ្រិចកើតស្រែងមួយជាតិ...» ។ ជាកំណាព្យរបស់ជីតាខ្ញុំខាងឪពុក គឺលោកតាម៉ម-សុទ្ធ ។ ពួកយើងគ្រាន់តែជាសត្វគីង្គក់ ដែលជិះលើស្លឹកឈើ បណ្ដែតតាមទឹកស្ទឹងទៅលេងក្រុងសៀមរាប ។

បើពួកយើងចង់កាត់ទោសលោកខៀវ-សំផន គឺយើងត្រូវទៅសុំសេចក្ដីអនុញ្ញាតពីលោកហ៊ុន-សែន ពីព្រោះលោកហ៊ុន-សែន ជានាយករដ្ឋមន្ត្រីបច្ចុប្បន្ន ។ ប៉ុន្តែបើយើងចង់កាត់ទោសលោកហ៊ុន-សែន យើងត្រូវទៅសុំសេចក្ដីអនុញ្ញាតរបស់លោកខៀវ-សំផន ពីព្រោះលោកខៀវ-សំផន ជាគ្រូឧបជ្ឈាយ៍របស់គាត់ ។ បើយើងចង់កាត់ទោសសម្ដេចសីហនុ វាមានតែទៅសុំអនុញ្ញាតពីខ្មោចលោកលន់-នល់ ដែលបានប្រាប់គេប្រាប់ឯង កាលពីគាត់នៅរស់ថា ៖ «ខ្ញុំមិនបានក្បត់សម្ដេចសីហនុទេ អ្វីៗដែលខ្ញុំបានធ្វើទាំងអស់ គឺជាព្រះរាជបញ្ជារបស់ព្រះអង្គ» ។

ចំណែកស្ដេចសីហនុវិញ ទ្រង់ចងអាឃាតព្យាបាទតែជាមួយពួកលន់-នល់ប៉ុណ្ណោះ បើគេរុញគាត់ឲ្យកាត់ទោសពួកមេដឹកនាំខ្មែរក្រហម គាត់បែរជារុញឲ្យគេកាត់ទោស «ពួកចាញ់នៃថ្ងៃ១៧មេសា»...

សម្រេចសម្រួចទៅ គឺពួកសត្វគីង្គក់ដដែល ដែលមានវាសនាចាំតែស្លាប់ «ទួលបង្គន់សមតែស្លាប់ !!» ...។

★ ★

★